# លទ្ធផលនៃការសិក្សាវិភាគ
# លើឥណទានមីក្រូហិរញ្ញវត្ថុ

## តុលា ឆ្នាំ២០១៦

ក្រុមស្រាវជ្រាវ

របស់

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

នៃ

## ទីស្តីការគណៈរដ្ឋមន្ត្រី

## មាតិកា


១.សេចក្តីផ្តើម ........ 1

២.រចនាសម្ព័ន្ធនិងចរិតលក្ខណៈវិស័យមីក្រូហិរញ្ញវត្ថុ ........ 1

    ក.មីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ ........ 1

    ខ.មីក្រូហិរញ្ញវត្ថុគ្មានអាជ្ញាបណ្ណ ........ 1

៣.អ្នកខ្ចីប្រាក់មីក្រូហិរញ្ញវត្ថុ ........ 2

៤.ប្រភពមូលធន ........ 2

៥.អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ ........ 4

៦.ឥណទានគ្រឹះស្ថានហិរញ្ញវត្ថុមានអាជ្ញាបណ្ណ ........ 4

៧.កត្តាកំណត់អាត្រាការប្រាក់ ........ 5

៨.ការវិភាគទិន្នន័យនៃកត្តាកំណត់អាត្រាការប្រាក់ ........ 6

    ក.គ្រឹះស្ថានធនាគារពាណិជ្ជ ........ 6

    ខ.គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ ........ 7

    គ.ការប្រៀបធៀបអាត្រាការប្រាក់របស់គ្រឹះស្ថានធនាគារពាណិជ្ជនិងមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ ........ 8

៩.សេចក្តីសន្និដ្ឋាននិងសំណើវិធានការ ........ 9

    ក.ថ្លៃដើមមូលធន ........ 9

    ខ.ចំណាយប្រតិបត្តិការ ........ 10

១០.ផលប៉ះពាល់អវិជ្ជមាននៃមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណនិងគ្មានអាជ្ញាបណ្ណ និងសំណើវិធានការ ........ 10

    ក.មីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ ........ 10

ខ.មីក្រូហិរញ្ញវត្ថុគ្មានអាជ្ញាបណ្ណ.....................................................................11
១១.កត្តារួមផ្សំផ្សេងទៀតដែលនាំឲ្យមានផលប៉ះពាល់អវិជ្ជមានក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងសំណើវិធានការ.....................................................................12

# លទ្ធផលនៃការសិក្សាវិភាគលើឥណទានមីក្រូហិរញ្ញវត្ថុ

## ១. សេចក្តីផ្តើម

ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) តែងតែទទួលបានពត៌មានជាច្រើនអំពីភាពអវិជ្ជមាននៃប្រជាពលរដ្ឋជាអ្នកខ្ចីប្រាក់មីក្រូហិរញ្ញវត្ថុ ដែលមិនមានលទ្ធភាពសងបំណុលបាន ហើយប្រឈមនឹងការរឹបអូសទ្រព្យធានា មានដូចជាផ្ទះសម្បែងដីធ្លីនិងទ្រព្យសម្បត្តិផ្សេងទៀត និងរងការជំពាក់បំណុលវ័ណ្ឌកដោះខ្លួនមិនរួច។

ECOSOCC បានធ្វើការសិក្សាស្រាវជ្រាវចំនួនពីរលើក គឺលើកទីមួយនៅឆ្នាំ២០១២ដោយផ្អែកលើទិន្នន័យនិងព័ត៌មានត្រឹមដំណាច់ឆ្នាំ២០១០ និងលើកទីពីរនៅដើមឆ្នាំ២០១៦ដោយផ្អែកលើទិន្នន័យនិងព័ត៌មានត្រឹមដំណាច់ឆ្នាំ២០១៥។

យោងតាមការសិក្សាទាំងពីរខាងលើ ECOSOCCយល់ឃើញថា អត្រាការប្រាក់ខ្ពស់គឺជាកត្តាចម្បងនៃភាពអវិជ្ជមានទាំងនោះ ហើយជាមួយគ្នានេះ ក៏មានកត្តារួមផ្សំផ្សេងទៀតបានចូលរួមចំណែកផងដែរ។

ទិន្នន័យនិងព័ត៌មានដែលបានលើកយកមកសិក្សា គឺជាទិន្នន័យផ្លូវការចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុចំនួនដប់ដែលមានអាជ្ញាបណ្ណ និងព័ត៌មានដែលទទួលបានពីមជ្ឈដ្ឋានផ្សេងទៀត។

## ២.រចនាសម្ព័ន្ធនិងចរិតលក្ខណៈវិស័យមីក្រូហិរញ្ញវត្ថុ

ដើម្បីមានមូលដ្ឋានងាយស្រួលក្នុងការពិនិត្យពិចារណារកមូលហេតុនៃភាពអវិជ្ជមាន ECOSOCC សូមបង្ហាញជូនអំពីរចនាសម្ព័ន្ធនិងចរិតលក្ខណៈនៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជានាពេលបច្ចុប្បន្នដូចខាងក្រោម៖

### ក. មីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ

១. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណផ្តល់ឥណទាននិងមានសិទ្ធិទទួលប្រាក់បញ្ញើពីសាធារណជន ជាប្រភេទគ្រឹះស្ថាន ស្ថិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។

២. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណផ្តល់ឥណទាន តែគ្មានសិទ្ធិទទួលប្រាក់បញ្ញើពីសាធារណជន គ្រឹះស្ថាននេះក៏ស្ថិតក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជាដែរ។

### ខ.មីក្រូហិរញ្ញវត្ថុគ្មានអាជ្ញាបណ្ណ

១. ប្រតិបត្តិករឥណទានដែលបានចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា គឺជាប្រភេទមីក្រូហិរញ្ញវត្ថុដែលមានការគ្រប់គ្រងធូរស្រាលនិងមិនមានទិន្នន័យជាផ្លូវការ ដែលត្រូវបានចងក្រងសម្រាប់ប្រតិបត្តិករឥណទានប្រភេទនេះទេ។

២. ឈ្មួញចងការប្រាក់និងអង្គការមិនមែនរដ្ឋាភិបាល ដោយតាំងខ្លួនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬឈ្មួញលក់វត្ថុប្រើប្រាស់បង់រំលស់ ធ្វើប្រតិបត្តិការឲ្យខ្ចីនៅក្រៅច្បាប់ដែលយកការប្រាក់កេងប្រវ័ញ្ចហួសហេតុ និងពេលខ្លះអនុវត្តវិធីព្រៃផ្សៃដើម្បីរឹបអូសយកទ្រព្យធានា ដោយមិនអនុវត្តតាមនីតិវិធីច្បាប់ត្រឹមត្រូវនៅពេលដែលអ្នកខ្ចីមិនអាចសងបំណុលបាន។

## ៣.អ្នកខ្ចីប្រាក់មីក្រូហិរញ្ញវត្ថុ

យោងតាមព័ត៌មាននិងស្ថានភាពបច្ចុប្បន្ន យើងអាចធ្វើចំណាត់ថ្នាក់អ្នកខ្ចីប្រាក់មីក្រូហិរញ្ញវត្ថុ ជាបួនប្រភេទ៖

១. អ្នកខ្ចីប្រាក់យកទៅប្រកបរបរអាជីវកម្ម ពោលគឺយកប្រាក់ទៅបង្កើតចំណូល មានដាក់វត្ថុធានា មានប្រវត្តិល្អក្នុងការខ្ចីដោយគោរពបានយ៉ាងល្អនូវកិច្ចសន្យាឥណទាន និងមានចំណេញសម្រាប់ជីវិតរស់នៅកាន់តែប្រសើរឡើង។ អ្នកខ្ចីប្រាក់ប្រភេទនេះមានលទ្ធភាពពេញលេញក្នុងការខ្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណដែលមានអត្រាការប្រាក់ទាប។

២. អ្នកខ្ចីយកទៅប្រកបរបរអាជីវកម្ម ពោលគឺយកប្រាក់ទៅបង្កើតចំណូល គ្មានដាក់វត្ថុធានា ក៏ប៉ុន្តែមានអ្នកធានាជាក្រុម។ អ្នកខ្ចីប្រាក់ប្រភេទនេះក៏អាចខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណបានដែរ ប៉ុន្តែអត្រាការប្រាក់អាចមានកម្រិតខ្ពស់ជាងប្រភេទខាងលើ។

៣. អ្នកខ្ចីប្រាក់ដែលពុំមានមុខរបរ ឬខ្ចីទៅសងបំណុលមួយទៀត ឬជំពាក់បំណុលគេវ័ណ្ឌក ឬខ្ចីយកទៅប្រើប្រាស់គ្មានចំណូលមកវិញ ឬដើម្បីដោះទាល់ អ្នកខ្ចីប្រាក់ប្រភេទនេះមិនអាចខ្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណបានទេ។ ជម្រើសតែមួយរបស់គាត់ គឺខ្ចីពីមីក្រូហិរញ្ញវត្ថុគ្មានអាជ្ញាបណ្ណ ដោយមិនគិតអំពីអត្រាការប្រាក់ខ្ពស់និងលទ្ធភាពសងបំណុលទេ។ អ្នកខ្ចីប្រាក់ប្រភេទនេះងាយរងគ្រោះបំផុតដោយការរឹបអូសទ្រព្យធានាពីម្ចាស់បំណុល។

## ៤. ប្រភពមូលធន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ មានប្រភពមូលធនបង្ហាញតាមតារាងដូចខាងក្រោម៖

គិតជា លាន ដុល្លារ

| | 2011 | 2012 | 2013 | 2014 |
|---|---|---|---|---|
| **១. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណផ្តល់ឥណទាន និងមានសិទ្ធិទទួលប្រាក់បញ្ញើពីសាធារណជន** | | | | |
| • ដើមទុនដែលបានបង់ | 41 | 58 | 60 | 100 |
| • ប្រាក់បញ្ញើទទួលបាន | 115 | 274 | 436 | 905 |
| • ប្រាក់កម្ចី | 331 | 457 | 686 | 836 |

| | | | | |
|---|---|---|---|---|
| **សរុប(១)** | **487** | **789** | **1,182** | **1,841** |
| **២. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណផ្តល់ឥណទាន តែគ្មានសិទ្ធិទទួលប្រាក់បញ្ញើពីសាធារណជន** | | | | |
| ដើមទុនដែលបានបង់ | 32 | 46 | 59 | 69 |
| **សរុប (១+២)** | **519** | **835** | **1,241** | **1,910** |

**ប្រភព:** របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា និងរបាយការណ៍ប្រចាំឆ្នាំរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណទទួលប្រាក់បញ្ញើ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមិនអាចទទួលប្រាក់បញ្ញើមានលទ្ធភាពតិចតួចក្នុងការខ្ចីបុលពីបរទេស។ គ្រឹះស្ថានទាំងនេះភាគច្រើនពឹងផ្អែកស្ទើរតែទាំងស្រុងលើដើមទុនផ្ទាល់ខ្លួនដើម្បីផ្តល់ឥណទាន ដែលដើមទុននោះមានទំហំតូចបើប្រៀបធៀបនឹងទំហំឥណទានសរុបរបស់វិស័យមីក្រូហិរញ្ញវត្ថុ។




ទិន្នន័យនេះឆ្លុះបញ្ចាំងអំពីស្ថានភាពមូលធនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណផ្តល់ឥណទាន និងមានសិទ្ធិទទួលប្រាក់បញ្ញើពីសាធារណជនចាប់ពីឆ្នាំ២០១១ដល់ឆ្នាំ២០១៤ ដែលមានការវិវត្តគួរឲ្យកត់សំគាល់ ពោលគឺដើមទុនដែលបានបង់មានការកើនឡើង តែតិចជាងកំណើននៃប្រាក់បញ្ញើពីសាធារណជន និងកំណើននៃប្រាក់កម្ចីដែលភាគច្រើនជាប្រាក់កម្ចីពីអង្គការហិរញ្ញវត្ថុក្រៅប្រទេស។ លក្ខណៈបែបនេះបានបង្ហាញអំពីទំនុកចិត្តរបស់សាធារណជននិងអង្គការទាំងនោះ មកលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានសិទ្ធិទទួលប្រាក់បញ្ញើ។

## ៥. អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ

ខាងក្រោមនេះ ជាតារាងទិន្នន័យបង្ហាញពីកំណើនចំនួនអ្នកខ្ចីប្រាក់សរុបពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ ពីឆ្នាំ២០០៥ដល់ឆ្នាំ២០១៤។

| 2005 | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 |
|---|---|---|---|---|---|---|---|---|---|
| 351,096 | 446,489 | 601,691 | 825,238 | 871,401 | 992,452 | 1,151,339 | 1,316,265 | 1,565,526 | 1,779,171 |

**ប្រភព**: របាយការណ៍ប្រចាំឆ្នាំ២០១៤របស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា




## ៦. ឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ

ខាងក្រោមនេះជាតារាងទិន្នន័យនៃការវិវត្តចំនួនទឹកប្រាក់ឥណទានសរុបនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ គិតជាលានដុល្លារ។

គិតជាលានដុល្លារ

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 |
|---|---|---|---|---|---|---|---|---|---|---|
| សមតុល្យឥណទាន | 50 | 87 | 154 | 277 | 299 | 426 | 645 | 893 | 1,325 | 2,029 |
| កំណើនឥណទាន | - | 37 | 67 | 123 | 22 | 127 | 219 | 248 | 433 | 703 |
| កំណើនឥណទាន (គិតជាភាគរយ) | - | 73% | 78% | 80% | 8% | 43% | 51% | 38% | 48% | 53% |

**ប្រភព**: របាយការណ៍ប្រចាំឆ្នាំ២០១៤របស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា




ឆ្លងតាមទិន្នន័យនេះ យើងសង្កេតឃើញអំពីកំណើនយ៉ាងខ្លាំងនៃឥណទាន ក៏ដូចជាចំនួនអ្នកខ្ចីប្រាក់ដែលបានជំរុញផលិតកម្មនិងសេវាកម្មខ្នាតតូច។

## ៧. កត្តាកំណត់អត្រាការប្រាក់

ខាងក្រោមនេះ ជាការវិភាគអំពីការវិវត្តនៃអត្រាការប្រាក់ ដោយយោងលើទិន្នន័យផ្លូវការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណចំនួន១០។ មានកត្តាសំខាន់ៗចំនួនបួនដែលបានចូលរួមចំណែកនាំឲ្យអត្រាការប្រាក់មានកម្រិតខ្ពស់ឬទាប រួមមាន (១)ថ្លៃដើមមូលធន (២)ចំណាយប្រតិបត្តិការ (៣)ហានិភ័យ និង(៤)ប្រាក់ចំណេញ។ កត្តាចូលរួមចំណែកមួយទៀត គឺអត្រាអតិផរណាត្រូវបានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណបញ្ចូលទៅក្នុងថ្លៃដើមមូលធនរួចហើយ។

១. បើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានលទ្ធភាពកេណ្ឌប្រមូលទុន(ប្រាក់កម្ចីឬប្រាក់បញ្ញើ)បានក្នុងតម្លៃទាប នោះអត្រាការប្រាក់ក៏នឹងអាចមានកម្រិតទាបតាមនោះដែរ ព្រោះថាថ្លៃដើមនេះ គឺអាស្រ័យទៅលើការសម្រេចរបស់ម្ចាស់មូលធន ដោយមិនទាក់ទងនឹងចេតនារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនោះទេ។

២. ចំណាយប្រតិបត្តិការ គឺជាកត្តាដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាចកាត់បន្ថយបាន ដោយការប្រើប្រាស់បច្ចេកវិទ្យាទំនើប ការបង្កើនផលិតភាពតាមរយៈការបណ្តុះបណ្តាលបុគ្គលិកជាប្រចាំ ឬការសន្សំសំចៃឲ្យបានជាអតិបរមាតាមដែលអាចធ្វើបាននៅក្នុងប្រតិបត្តិការរបស់ខ្លួន។

៣. ហានិភ័យនៅទីនេះ សំដៅដល់ហានិភ័យនៃការមិនអាចប្រមូលបំណុលបានវិញ។ ហានិភ័យអាចកើតឡើងដោយកត្តាជាច្រើន ដូចជាកូនបំណុលមិនអាចសងបំណុលដោយសារតែការខាតបង់ក្នុងអាជីវកម្មដែលមកពីការគ្រប់គ្រងមិនល្អ(ខ្វះសហគ្រិនភាព) ឬគ្រោះធម្មជាតិ ឬការធ្លាក់ថ្លៃផលិត

ផល។ ជាការពិត រាល់ការប្រកបអាជីវកម្មតែងតែជួបនឹងហានិភ័យ មិនអាចជៀសផុតទោះតិចក្តី ច្រើនក្តី គឺអាស្រ័យលើសមត្ថភាពនៃការយល់ដឹងអំពីមូលហេតុដែលនាំឲ្យកើតហានិភ័យ ការគ្រប់គ្រងហានិភ័យ ព្រមទាំងដំណោះស្រាយបញ្ហាដែលកើតឡើងពីហានិភ័យ។ ហានិភ័យនៅពេលដែលកើតឡើងហើយ វាប៉ះពាល់ទាំងសងខាងរវាងភាគីអ្នកខ្ចីប្រាក់និងភាគីអ្នកឲ្យខ្ចី គឺភាគីអ្នកខ្ចីប្រាក់ប្រឈមនឹងការរឹបអូសទ្រព្យធានា និងវិធានការតាមផ្លូវតុលាការ និងអាចធ្លាក់ខ្លួនក្រីក្រវីឯភាគីអ្នកឲ្យខ្ចីប្រឈមនឹងការបាត់បង់ដើមទុនដែលជារបស់អ្នកផ្ញើប្រាក់ ជាប្រាក់កម្ចីនិងជារបស់ភាគទុនិក ហើយអាចឈានដល់ការក្ស័យធន បិទទ្វារលែងធ្វើអាជីវកម្ម និងនាំឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សាធារណជន អ្នកផ្ញើប្រាក់និងវិនិយោគិន។ ផលប៉ះពាល់ធ្ងន់ធ្ងរជាងនេះទៅទៀត គឺអាចបាត់បង់ទំនុកចិត្តលើប្រព័ន្ធហិរញ្ញវត្ថុទាំងមូលពីសំណាក់សាធារណជន អ្នកផ្ញើប្រាក់និងពីវិនិយោគិន។

**៤.** ប្រាក់ចំណេញ គឺជាលទ្ធផលនៃប្រតិបត្តិការ។ ក្នុងខណៈដែលមានការប្រកួតប្រជែងខ្លាំង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាចបន្ថយប្រាក់ចំណេញរបស់ខ្លួនឲ្យនៅត្រឹមកម្រិតសមរម្យ ដែលវិនិយោគិនជាភាគទុនិកអាចទទួលយកបាន។ បើគ្រឹះស្ថានមិនមានប្រាក់ចំណេញសមរម្យទេនោះ វិនិយោគិនជាភាគទុនិកអាចនឹងបិទទ្វារគ្រឹះស្ថាន ដែលនាំឲ្យប្រជាពលរដ្ឋបាត់បង់ឱកាសក្នុងការខ្ចីទុនយកទៅប្រកបអាជីវកម្ម ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួន។

ការកំណត់អត្រាការប្រាក់ គឺជាការគិតគូរព្យាករជាមុនដោយផ្អែកលើកត្តាទាំងបួនខាងលើ និងអាស្រ័យទៅលើភាពសម្បូរបែបនៃប្រភពទុននិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបង្កលក្ខណៈឲ្យមានការប្រកួតប្រជែងកាន់តែខ្លាំងក្លាឡើងក្នុងទីផ្សារនិងទាញអត្រាការប្រាក់ឲ្យថយចុះ។

## ៨. ការវិភាគទិន្នន័យនៃកត្តាកំណត់អត្រាការប្រាក់

ខាងក្រោមនេះ គឺជាតារាងប្រៀបធៀបនៃការវិវត្តកត្តាកំណត់អត្រាការប្រាក់របស់គ្រឹះស្ថានធនាគារពាណិជ្ជចំនួន១០ និងមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណចំនួន១០ ក្នុងរយៈពេល៥ឆ្នាំ គិតពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៤៖

### ក. គ្រឹះស្ថានធនាគារពាណិជ្ជ

| កត្តាចូលរួម | 2010 | 2011 | 2012 | 2013 | 2014 |
|---|---|---|---|---|---|
| ថ្លៃដើមមូលធន | 4.7% | 4.1% | 3.9% | 3.7% | 3.3% |
| ចំណាយប្រតិបត្តិការ | 5.3% | 4.3% | 3.9% | 4.0% | 3.7% |
| ហានិភ័យ | 3.8% | 2.2% | 2.3% | 2.7% | 2.1% |
| ប្រាក់ចំណេញ | 3.0% | 3.6% | 3.7% | 2.8% | 3.4% |
| **សរុប** | **16.8%** | **14.2%** | **13.8%** | **13.2%** | **12.5%** |

**ប្រភព:** របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ២០១០-២០១៤ របស់ធនាគារជាតិនៃកម្ពុជា និងរបាយការណ៍ប្រចាំឆ្នាំ២០១០-២០១៤របស់គ្រឹះស្ថានធនាគារពាណិជ្ជទាំង១០ គឺ (១)ធនាគារកាណាឌីយ៉ា (២) ធនាគារអេអ៊ិនហ្សេតរ៍យ៉ាល (៣)ធនាគារអេស៊ីលីដា (៤)ធនាគារកម្ពុជាសាធារណៈ (៥)ធនាគារពាណិជ្ជកម្មក្រៅប្រទេស (៦)ធនាគារវឌ្ឍនៈអាស៊ី(ABA) (៧)ធនាគារវឌ្ឍនៈ(Vattanac) (៨)ធនាគារសហពាណិជ្ជ (៩)ធនាគារវិនិយោគនិងអភិវឌ្ឍន៍កម្ពុជា និង (១០)ធនាគារមេយប៉ែងកម្ពុជា




ទិន្នន័យនៅក្នុងតារាងខាងលើនេះបង្ហាញថា អត្រាការប្រាក់ឲ្យខ្ចីជាមធ្យមរបស់គ្រឹះស្ថានធនាគារពាណិជ្ជទាំង១០ បានថយចុះពី១៦,៨%នៅឆ្នាំ២០១០ មកត្រឹម១២,៥%នៅឆ្នាំ២០១៤។

## ខ. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ

| កត្តាចូលរួម | 2010 | 2011 | 2012 | 2013 | 2014 |
|---|---|---|---|---|---|
| ថ្លៃដើមមូលធន | 6.4% | 5.7% | 6.4% | 6.2% | 6.2% |
| ចំណាយប្រតិបត្តិការ | 13.3% | 11.6% | 11.9% | 10.7% | 9.5% |
| ហានិភ័យ | 1.0% | 0.4% | 0.5% | 0.4% | 0.5% |

| | | | | | |
|---|---|---|---|---|---|
| ប្រាក់ចំណេញ | 3.5% | 4.3% | 4.4% | 4.0% | 4.3% |
| **សរុប** | **24.4%** | **22.0%** | **23.1%** | **21.3%** | **20.5%** |

**ប្រភព**: របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ២០១០-២០១៤របស់ធនាគារជាតិនៃកម្ពុជា និងរបាយការណ៍ប្រចាំឆ្នាំ២០១០-២០១៤របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណទាំង១០ គឺ (១)ស្ថាបនា (២)ប្រាសាក់ (៣)វីសិនហ្វាន់ (៤)អម្រឹត (៥)ហត្ថាកសិករ (៦)អេអឹមខេ (៧)គ្រេឌីត (៨)ធនាគារភូមិ (៩)សំរឹទ្ធិស័ក និង (១០)ហ្វីសហ្វាយនែន




ទិន្នន័យនៅក្នុងតារាងខាងលើនេះបង្ហាញថា អត្រាការប្រាក់ឲ្យខ្ចីជាមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណទាំង១០ បានថយចុះពី២៤,៤%នៅឆ្នាំ២០១០មកត្រឹម២០,៥%នៅឆ្នាំ២០១៤។

## គ. ការប្រៀបធៀបអត្រាការប្រាក់របស់គ្រឹះស្ថានធនាគារពាណិជ្ជនិងមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ

យោងតាមការសិក្សាវិភាគទៅលើព័ត៌មាននិងទិន្នន័យខាងលើ ECOSOCCមានសេចក្តីសន្និដ្ឋានដូចខាងក្រោម៖

ប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារពាណិជ្ជនិងមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ បានប្រព្រឹត្តទៅយ៉ាងល្អប្រសើរ ដោយសារតែគ្រឹះស្ថានទាំងនោះស្ថិតនៅក្រោមច្បាប់និងបទបញ្ញត្តិត្រួតពិនិត្យត្រឹមត្រូវ។

លើសពីនេះ គ្រឹះស្ថានទទួលបានទំនុកចិត្ត អាចកេណ្ឌប្រមូលប្រភពមូលធនជាច្រើនដើម្បីផ្តល់ប្រាក់កម្ចីដល់សាធារណជន យកទៅប្រើប្រាស់ដើម្បីប្រកបអាជីវកម្ម លើកកម្ពស់ជីវភាពរស់នៅ និងរួមចំណែកបង្កើនកំណើនសេដ្ឋកិច្ច។ គួរកត់សម្គាល់ថាប្រជាពលរដ្ឋដែលមានលទ្ធភាពទទួលសេវាហិរញ្ញវត្ថុពីគ្រឹះស្ថានទាំងនោះ មានកាន់តែច្រើនឡើងជារៀងរាល់ឆ្នាំ។

អត្រាការប្រាក់មធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ បានថយចុះពី២៤,៥%នៅឆ្នាំ២០១០ មកត្រឹម២០,៥%នៅឆ្នាំ២០១៤ ដែលជាលទ្ធផលនៃការថយចុះចំណាយប្រតិបត្តិការ។ ECOSOCCយល់ឃើញថា អត្រានេះនឹងថយចុះថែមទៀត នៅពេលដែលថ្លៃដើមមូលធននិងចំណាយប្រតិបត្តិការត្រូវបានកាត់បន្ថយ តាមរយៈពិពិធកម្មប្រភពមូលធននិងការប្រើប្រាស់បច្ចេកវិទ្យាទំនើបដើម្បីបម្រើឲ្យប្រតិបត្តិការដូចជាការផ្តល់ឥណទាននិងការប្រមូលបំណុលជាដើម។

ទិន្នន័យខាងលើបង្ហាញថា អត្រាការប្រាក់របស់គ្រឹះស្ថានធនាគារពាណិជ្ជនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ មាននិន្នាការថយចុះដូចគ្នា។ ប៉ុន្តែអត្រាការប្រាក់របស់គ្រឹះស្ថានធនាគារពាណិជ្ជ មានកម្រិតទាបជាងអត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ ដោយមូលហេតុថ្លៃដើមមូលធននិងចំណាយប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារពាណិជ្ជ ទាបជាងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ។

## ៩.សេចក្តីសន្និដ្ឋាននិងសំណើវិធានការ

ការវិភាគខាងលើបានបង្ហាញថា នៅដំណាច់ឆ្នាំ២០១៤ ហានិភ័យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ មានកម្រិតក្រោម១% ដែលជាអត្រាទាបបំផុត រីឯប្រាក់ចំណេញវិញមានកម្រិត៤.៣%។

ដោយឡែក ទិន្នន័យបានបង្ហាញថា អត្រាការប្រាក់បច្ចុប្បន្ននៅមានកម្រិតខ្ពស់នៅឡើយ ទោះបីជាមានការថយចុះជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំក៏ដោយ។ អត្រាការប្រាក់ខ្ពស់នេះជាមូលហេតុមួយនាំឲ្យថ្លៃដើមផលិតផលកសិកម្ម សេវាកម្ម និងឧស្សាហកម្មធុនតូចនិងមធ្យមមានកម្រិតខ្ពស់ មិនអាចប្រកួតប្រជែងលើទីផ្សារជាតិនិងអន្តរជាតិបាន។

ECOSOCCយល់ឃើញថា អត្រាការប្រាក់នឹងថយចុះបានទៀត ប្រសិនបើថ្លៃដើមមូលធននិងចំណាយប្រតិបត្តិការត្រូវបានកាត់បន្ថយថែមទៀត៖

### ក. ថ្លៃដើមមូលធន

មូលហេតុដែលនាំឲ្យថ្លៃដើមមូលធនខ្ពស់ គឺបណ្តាលមកពីកង្វះប្រភពមូលធនសម្បទានដែលមានតម្លៃទាប ដោយសារថាប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍ ដូច្នេះចំណាត់ថ្នាក់ហានិភ័យឥណទានមានកម្រិតខ្ពស់ នាំឱ្យអត្រាការប្រាក់កម្ចីពីក្រៅប្រទេសមានកម្រិតខ្ពស់ផងដែរ រីឯលទ្ធភាពកៀរគរប្រាក់សន្សំក្នុងប្រទេសមានទំហំតូចៗ ហើយមានអត្រាការប្រាក់ខ្ពស់ជាងធនាគារពាណិជ្ជ។

ដូច្នេះ ដើម្បីឲ្យថ្លៃដើមមូលធនថយចុះបាន គួរតែមានវិធានការមួយចំនួនដូចខាងក្រោម៖

១. បង្កើនការកេណ្ឌប្រមូលធនធាន តាមរយៈពិពិធកម្មប្រភពធនធាន ការលើកកម្ពស់អន្តរការិយកម្មធនាគារក្នុងការបែងចែកធនធាន និងសម្រួលការសន្សំនិងវិនិយោគ។

២. ជំរុញឲ្យមានការប្រកួតប្រជែងនៅក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ ក្នុងគោលបំណងកាត់បន្ថយអត្រាការប្រាក់ និងជំរុញនវានុវត្តន៍ហិរញ្ញវត្ថុនិងកំណើនសេដ្ឋកិច្ច។

៣. ជំរុញដំណើរការទីផ្សារអន្តរធនាគារ ដោយផ្សារភ្ជាប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ ដើម្បីឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណអាចខ្ចីទុនពីគ្រឹះស្ថានធនាគារកាន់តែច្រើនឡើង។

៤. បញ្ច្រាបការយល់ដឹងជាទូទៅដល់សាធារណជនឲ្យមានចំណេះដឹងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងមានចំណេះដឹងជាមូលដ្ឋានក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ ដូចជាការដាក់ប្រាក់សន្សំនិងការខ្ចីប្រាក់ជាដើម។ ការងារនេះអាចត្រូវធ្វើឡើងដោយគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬតាមមធ្យោបាយអប់រំសមស្របផ្សេងទៀត។

៥. គួរមានអន្តរាគមន៍របស់រាជរដ្ឋាភិបាលក្នុងការរកប្រភពធនធាន ដែលមានអត្រាការប្រាក់សម្បទានពីក្រៅប្រទេស ដើម្បីឲ្យមានទុនសម្បូរបែប និងទាញឲ្យអត្រាការប្រាក់ថយចុះ។

### ខ. ចំណាយប្រតិបត្តិការ

ដើម្បីឲ្យចំណាយប្រតិបត្តិការថយចុះបាន គួរតែមានវិធានការមួយចំនួនដូចខាងក្រោម៖

១. បង្កើនផលិតភាព តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាទំនើបនិងការបណ្តុះបណ្តាលបុគ្គលិកជាប្រចាំ។

២. ប្រើប្រាស់ភ្នាក់ងារដើម្បីផ្ទេរប្រាក់កម្ចីនិងប្រមូលបំណុល។

៣. សន្សំសំចៃឲ្យបានជាអតិបរមាតាមដែលអាចធ្វើបាន។

## ១០.ផលប៉ះពាល់អវិជ្ជមាននៃមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណនិងគ្មានអាជ្ញាបណ្ណ និងសំណើវិធានការ

### ក. មីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ

#### ផលប៉ះពាល់អវិជ្ជមាន៖

១. បើប្រៀបធៀបព័ត៌មាននិងទិន្នន័យនៃអត្រាការប្រាក់មធ្យមដែលECOSOCCទទួលបាន យើងសង្កេតឃើញថាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណខ្លះ បានអនុវត្តយកអត្រាការប្រាក់ឲ្យខ្ចីលើសពីអត្រាមធ្យមនេះ។

២. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណខ្លះ មិនបានសិក្សាតាមដាននិងវាយតម្លៃឲ្យបានហ្មត់ចត់ទៅលើទិសដៅប្រើប្រាស់ឥណទាននិងលទ្ធភាពសងប្រាក់របស់អ្នកខ្ចីប្រាក់ ដោយ

ពឹងផ្អែកតែទៅលើទ្រព្យធានា។ នៅពេលដែលកូនបំណុលមិនអាចសងបំណុលបាន ក៏មានវិធានការរឹបអូសទ្រព្យទ្រព្យធានា។

**សំណើវិធានការ**

វិធានការដែលត្រូវយកមកដោះស្រាយបញ្ហាអវិជ្ជមាន គឺការពង្រឹងការអនុវត្តច្បាប់ឲ្យកាន់តែមានប្រសិទ្ធភាពឡើង ដោយហេតុថាមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ ស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

## ខ. មីក្រូហិរញ្ញវត្ថុគ្មានអាជ្ញាបណ្ណ

**ផលប៉ះពាល់អវិជ្ជមាន**

ECOSOCCមិនមានទិន្នន័យនៃទំហំមូលធនរបស់មីក្រូហិរញ្ញវត្ថុគ្មានអាជ្ញាបណ្ណ ដែលបានធ្វើប្រតិបត្តិការឲ្យខ្ចីប្រាក់ គ្រាន់តែបានព័ត៌មានថា ទំហំនៃមូលធននោះមិនធំទេ ប៉ុន្តែអត្រាការប្រាក់ខ្ពស់កេងប្រវ័ញ្ចហួសហេតុ ទោះជាយកទៅប្រកបរបរបានចំណូលយ៉ាងណាក៏ដោយ ក៏មិនអាចសងការប្រាក់រួចដែរ ដែលជាហេតុនាំឲ្យមានភាពអវិជ្ជមានកើតឡើងជាច្រើន។

ផលប៉ះពាល់អវិជ្ជមានដែលកើតចេញពីមីក្រូហិរញ្ញវត្ថុគ្មានអាជ្ញាបណ្ណរួមមាន៖

១. ការធ្វើសកម្មភាពធនាគារដោយខុសច្បាប់ នាំឲ្យខូចសណ្តាប់ធ្នាប់ទីផ្សារ។

២. ការផ្តល់កម្ចីដោយធូររលុង បណ្តាលឲ្យប្រជាពលរដ្ឋជំពាក់បំណុលវណ្ឌក។

៣. ការបន្លំខ្លួនជាមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណឬអង្គការរដ្ឋ ដែលការពិតអង្គការនេះមិនមានទាល់តែសោះ ជាហេតុបង្កឲ្យមតិសាធារណជនមានការភន្តច្រឡំ។

៤. ការអនុវត្តអត្រាការប្រាក់ខ្ពស់ ការកេងប្រវ័ញ្ចហួសហេតុ និងការគិតគូរការប្រាក់ដោយបន្លំគ្មានតម្លាភាព។

៥. ការអនុវត្តរឹបអូសទ្រព្យធានាតាមវិធីអមនុស្សធម៌ ដោយមិនគោរពតាមនីតិវិធីច្បាប់។

**សំណើវិធានការ**

ដើម្បីកាត់បន្ថយឲ្យបានជាអតិបរមានូវបញ្ហាអវិជ្ជមាន ដែលបង្កឡើងដោយមីក្រូហិរញ្ញវត្ថុគ្មានអាជ្ញាបណ្ណទៅលើប្រជាពលរដ្ឋក្រីក្រដូចពេលបច្ចុប្បន្ននេះ ECOSOCCយល់ថាគួរតែមានវិធានការដូចខាងក្រោម៖

១. អនុវត្តច្បាប់ស្តីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាពិសេសមាត្រា៥៥ ចំណុចទី១- "បុគ្គលណា ជាឯកត្តជនក្តីឬក្នុងនាមអង្គភាពក្តី ដែលយកប្រតិបត្តិការធនាគារជាវិជ្ជាជីវៈជា

ប្រក្រតីនិងសម្រាប់សាធារណជនដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ(១ឆ្នាំ) ដល់ប្រាំឆ្នាំ(៥ឆ្នាំ) និងពិន័យជាប្រាក់ពីប្រាំលានរៀល (៥,០០០,០០០៛) ដល់ពីររយហាសិបលានរៀល(២៥០,០០០,០០០៛) ឬទណ្ឌកម្មតែមួយក្នុងទណ្ឌកម្មទាំងពីរ ដោយមិនទាន់គិតដល់ការបិទគ្រឹះស្ថានផង។" ដោយអនុញ្ញាតឲ្យធ្វើប្រតិបត្តិការឥណទានចំពោះគ្រឹះស្ថានហិរញ្ញវត្ថុណា ដែលមានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាតែប៉ុណ្ណោះ និងបំបាត់ចោលអ្នកដែលធ្វើប្រតិបត្តិការធនាគារដោយគ្មានអាជ្ញាបណ្ណ។

២. ចំពោះប្រតិបត្តិករឥណទានដែលចុះបញ្ជី ត្រូវតែប្រែក្លាយខ្លួនទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ ហើយលុបបំបាត់ចោលប្រតិបត្តិករឥណទានចុះបញ្ជីនេះចេញពីប្រព័ន្ធ ព្រោះថា ប្រតិបត្តិករឥណទាននេះមិនបានស្ថិតនៅក្រោមការត្រួតពិនិត្យហ្មត់ចត់ពីធនាគារជាតិនៃកម្ពុជា ដូចគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណឡើយ។

## ១១. កត្តារួមផ្សំផ្សេងទៀតដែលនាំឲ្យមានផលប៉ះពាល់អវិជ្ជមានក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងសំណើវិធានការ

យោងតាមការសិក្សានិងវិភាគទៅលើទិន្នន័យនិងព័ត៌មានជាក់ស្តែង ECOSOCCបានកត់សម្គាល់ឃើញមានភាពអវិជ្ជមានខ្លះទៀតក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ដែលកើតឡើងពីកត្តារួមផ្សំមួយចំនួនដូចខាងក្រោម៖

១. កង្វះការយល់ដឹងរបស់អ្នកខ្ចីប្រាក់អំពីកាតព្វកិច្ចរបស់ខ្លួនក្នុងកិច្ចសន្យាខ្ចីប្រាក់ ដោយមិនបានពិចារណាល្អិតល្អន់អំពីលក្ខខណ្ឌរបស់អ្នកឲ្យខ្ចី និងមិនបានគិតថា ពេលចុះកិច្ចសន្យាខ្ចីហើយត្រូវតែមានកាតព្វកិច្ចសងវិញ ខ្ចីដោះទាល់ឲ្យរួចមួយពេលៗ មិនយកទៅប្រកបរបររកចំណូល។

២. ការរកស៊ីខាតក្នុងមុខរបរដោយអត់សមត្ថភាពក្នុងការគ្រប់គ្រង ឬគ្មានមុខជំនាញ ឬខ្វះសហគ្រិនភាព ឬរងឥទ្ធិពលនៃវិបត្តិផ្សេងៗ ឬដោយគ្រោះធម្មជាតិដូចជាទឹកជំនន់ ភាពរាំងស្ងួត សត្វល្អិតបំផ្លាញផលដំណាំ។ល។

៣. ការចុះបញ្ជីដីធ្លីឲ្យទៅជាកម្មសិទ្ធិស្របច្បាប់មិនទាន់បានគ្រប់ជ្រុងជ្រោយ ដោយភាគច្រើននៅតែជាលិខិតកាន់កាប់ដីធ្លីដែលចេញដោយអាជ្ញាធរឃុំសង្កាត់ ងាយស្រួលក្លែងបន្លំដូចជាដីឬផ្ទះតែមួយអាចធ្វើបានលិខិតកាន់កាប់ពីរឬបីច្បាប់ អាចយកទៅដាក់បញ្ចាំខ្ចីប្រាក់ជាច្រើនកន្លែង ធ្វើឲ្យអ្នកខ្ចីប្រាក់ជំពាក់បំណុលវណ្ឌក ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ម្ចាស់បំណុលងាយរឹបអូសយកទ្រព្យធានា។

៤. អាជ្ញាធរឃុំសង្កាត់ខ្លះបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់ និងជួយប្រមូលបំណុលឲ្យម្ចាស់បំណុលជូនកាលអាចគាបសង្កត់ឲ្យអ្នកខ្ចីប្រាក់ផ្ទេរសិទ្ធិកាន់កាប់ទ្រព្យធានា ឲ្យម្ចាស់បំណុលទៀតផង។

## សំណើវិធានការ

ដើម្បីគាំទ្រនិងការពារប្រជាពលរដ្ឋឲ្យជៀសផុតពីផលប៉ះពាល់អវិជ្ជមានខាងលើ គួរមានវិធានការទ្រទ្រង់មួយចំនួនដូចខាងក្រោម៖

១. បន្តការផ្សព្វផ្សាយនិងអប់រំប្រជាពលរដ្ឋអំពីចំណេះដឹងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមូលដ្ឋានសំខាន់ៗ ដែលអាចមានឥទ្ធិពលលើមុខរបរនិងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

២. ពន្លឿនការចុះបញ្ជីដីធ្លី។

៣. អប់រំអាជ្ញាធរមូលដ្ឋានឲ្យបានយល់ច្បាស់អំពីតម្លៃខាងផ្លូវច្បាប់នៃលិខិតបទដ្ឋានគតិយុត្ត និងអំពីព្រំដែននៃការទទួលខុសត្រូវរបស់ខ្លួនក្នុងការចុះហត្ថលេខាបញ្ជាក់លើលិខិតស្នាមខ្ចីប្រាក់ ដើម្បីកុំឲ្យក្លាយខ្លួនជាអ្នកចូលរួមចំណែកជួយម្ចាស់បំណុល ក្នុងការទារបំណុលនិងគាបសង្កត់អ្នកខ្ចីប្រាក់ឲ្យប្រគល់ទ្រព្យធានាដោយខុសពីនីតិវិធីច្បាប់។

៤. បន្តរក្សាថ្លៃកសិផលតាមតម្លៃទីផ្សារនៅរដូវប្រមូលផល ជៀសវាងកុំឲ្យឈ្មួញបន្ថោកតម្លៃតាមចិត្ត ដោយរដ្ឋចូលអន្តរាគមន៍ក្នុងការប្រមូលទិញ ឬដោយស្វែងរកទីផ្សារសម្រាប់កសិផល។

៥. ពង្រឹងការប្រើប្រាស់ផលិតផលក្នុងស្រុក។